ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករទូរគមនាគមន៍កម្ពុជា

លេខ : ១៥៦៨....ន.ទ.ក.

# សេចក្តីណែនាំ
# ស្តីពី
# ការស្នើសុំលិខិតអនុញ្ញាតចុះឈ្មោះគេហទំព័រ .KH

និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក.) មានកិត្តិយសសូមគោរពជម្រាបជូន ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា៖ ដើម្បីទទួលបានលិខិតអនុញ្ញាតចុះឈ្មោះគេហទំព័រ .kh នៅក្នុងព្រះរាជាណាចក្រកម្ពុជា បុគ្គលទាំងឡាយជាជនជាតិខ្មែរ ឬ ជនជាតិបរទេស ត្រូវដាក់ពាក្យស្នើសុំមក ន.ទ.ក.។ ដើម្បីបង្កើនភាពងាយស្រួលដល់អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត ន.ទ.ក. សូមធ្វើការណែនាំអំពីនីតិវិធី និងឯកសារតម្រូវដូចខាងក្រោម៖

## ក. សេវា

- លិខិតអនុញ្ញាតចុះឈ្មោះគេហទំព័រ .KH (Domain Name System)

## ខ. ស្ថាប័នផ្តល់សេវា

និយ័តករទូរគមនាគមន៍កម្ពុជា៖

- បញ្ជរអតិថិជន (ផ្នែកប្រឹក្សាព័ត៌មាន ទទួលពាក្យ បង់កម្រៃពាក្យសុំ និងទទួលលិខិតអនុញ្ញាត)
- អាសយដ្ឋាន៖ អគារ ន.ទ.ក. វិថីលេខ ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
    - ទូរស័ព្ទ៖ ១២៧២ ឬ ០២៣ ៧២ ២៣ ៣៣
    - ទូរសារ៖ ០២៣ ៧២ ៣២ ២២
    - អ៊ីម៉ែល៖ frontdesk@trc.gov.kh

ក្នុងករណីដាក់ពាក្យដោយប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម៖

- គេហទំព័រ៖ www.trc.gov.kh/online

## គ. គោលបំណងនៃការផ្តល់សេវា

ផ្តល់ការគ្រប់គ្រងប្រព័ន្ធនិងសេវាគេហទំព័រ .KH (Domain Name System) នៅលើបណ្តាញអ៊ិនធឺណិតឱ្យមានប្រសិទ្ធភាពតាមបទដ្ឋានអន្តរជាតិ និងបើកទូលាយឱ្យមានការប្រើប្រាស់គេហទំព័រជាតិជូនដល់ក្រសួង/ស្ថាប័នរដ្ឋ អង្គការ ក្រុមហ៊ុន និងប្រជាពលរដ្ឋទូទៅ ។

## ឃ. មូលដ្ឋានគតិយុត្ត

- ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- ប្រកាសលេខ ១២២ បទ.ប្រក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការកែប្រែ ការព្យួរ ការផ្ទេរ និង ការដកហូត លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍

- ប្រកាសលេខ ១៥៥ ប.ទ.ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០១ស្តីពីការរៀបចំ និងការគ្រប់គ្រងប្រព័ន្ធ និងសេវាអ៊ីនធឺណែត និងប្រភេទសេវា VoIP នៅព្រះរាជាណាចក្រកម្ពុជា
- ប្រកាសរួមលេខ៤៩៨ សហវ.ប្រក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។
- ប្រកាសរួមលេខ៤៩៩ សហវ.ប្រក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈដោយនិយ័តករទូរគមនាគមន៍កម្ពុជា ។
- សារាចរអន្តរក្រសួងលេខ ០០១សរ.មផ-បទ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការគ្រប់គ្រងការធ្វើអាជីវកម្ម និងការប្រើប្រាស់សេវាកម្មទូរគមនាគមន៍
- លិខិតលេខ ១៨០៨ ប.ទ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ ស្តីពីបទប្បញ្ញត្តិនៃការចុះឈ្មោះគេហទំព័រ .kh ។ ។

## ខ. អតិថិជនដែលមានសិទ្ធិទទួលសេវា

ជនជាតិខ្មែរ ឬ ជនបរទេស ជារូបវន្តបុគ្គល ឬ នីតិបុគ្គល។

## ច. ស្តង់ដាសេវា

### ១. រយៈពេលផ្តល់សេវា

- ១០ ថ្ងៃ (ថ្ងៃធ្វើការ) សម្រាប់ការពិនិត្យ វាយតម្លៃ និងសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតបន្ទាប់ពីអ្នកស្នើសុំបានបំពេញពាក្យស្នើសុំត្រឹមត្រូវ និងផ្តល់ឯកសារគ្រប់គ្រាន់។

### ២. កម្រៃ

អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតត្រូវបង់៖

- កម្រៃសម្រាប់ការពិនិត្យ វាយតម្លៃ និងសម្រេចលើពាក្យស្នើសុំជូន ន.ទ.ក. ចំនួន ៤០.០០០ (សែសិបពាន់) រៀល (លើកលែងស្ថាប័នរដ្ឋដែលប្រើ .gov.kh ត្រូវផ្តល់ជូនដោយពុំគិតកម្រៃ)។
- កម្រៃប្រចាំឆ្នាំជូនក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (នាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ)
    - ១២០.០០០ (ដប់ពីរម៉ឺន) រៀល សម្រាប់រូបវន្តបុគ្គល ឬ នីតិបុគ្គលទូទៅ (.com.kh, .org.kh, .edu.kh, .net.kh, .mil.kh)
    - ៤០.០០០ (បួនម៉ឺន) រៀល សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន (.per.kh)
    - ចំពោះស្ថាប័នរដ្ឋដែលប្រើប្រាស់ .gov.kh ត្រូវផ្តល់ជូនដោយពុំគិតកម្រៃប្រចាំឆ្នាំ ។
- ចំពោះកម្រៃប្រចាំឆ្នាំដំបូងសម្រាប់ការផ្តល់លិខិតអនុញ្ញាត ត្រូវគិតតាមរយៈពេលនៅសល់ក្នុងឆ្នាំដូចខាងក្រោម ៖
    - រយៈពេលនៅសល់មិនលើស ៦ខែ ត្រូវគិតកម្រៃ ៥០% (ហាសិបភាគរយ) នៃកម្រៃប្រចាំឆ្នាំ
    - រយៈពេលនៅសល់លើសពី ៦ខែ ត្រូវគិតកម្រៃពេញមួយឆ្នាំនៃកម្រៃប្រចាំឆ្នាំ។

## ឆ. ឯកសារតម្រូវដើម្បីទទួលបានសេវា

អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត ត្រូវបំពេញពាក្យសុំដូចមានគំរូនៅក្នុងឧបសម្ព័ន្ធទី១ និង ត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

- **សម្រាប់គេហទំព័រប្រភេទ .gov.kh និង .mil.kh**
    - លិខិតស្នើសុំជាផ្លូវការពីស្ថាប័នសាមី.......................................................... ០១ច្បាប់
    - លិខិតបញ្ជាក់ការប្រគល់សិទ្ធិកាន់កាប់គេហទំព័រ និងភ្ជាប់ជាមួយនូវច្បាប់ចម្លងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬ បណ្ណមន្ត្រីរាជការរបស់អ្នកទទួលសិទ្ធិ ............................................០១ច្បាប់

- **សម្រាប់គេហទំព័រប្រភេទ .com.kh, .net.kh**
  - ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម........................................................ ០១ច្បាប់
  - ច្បាប់ចម្លងសម្រង់ព័ត៌មានក្រុមហ៊ុនចុះបញ្ជីពាណិជ្ជកម្ម.......................................... ០១ច្បាប់
  - ច្បាប់ចម្លងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន......................................០១ច្បាប់
  - ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីម៉ាក (Trademark) ប្រសិនមាន................................ ០១ច្បាប់
- **សម្រាប់គេហទំព័រប្រភេទ .org.kh**
  - ច្បាប់ចម្លងលិខិតអនុញ្ញាតដែលចេញដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រាប់អង្គការក្រៅរដ្ឋាភិបាល..................................................................០១ច្បាប់
  - ច្បាប់ចម្លងលិខិតអនុញ្ញាតដែលចេញដោយក្រសួងមហាផ្ទៃសម្រាប់អង្គការ ឬសមាគមក្នុងស្រុក.............................................................................................................. ០១ច្បាប់
  - ច្បាប់ចម្លងបណ្ណសម្គាល់ខ្លួន ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន....... ០១ច្បាប់
- **សម្រាប់គេហទំព័រប្រភេទ .edu.kh**
  - ច្បាប់ចម្លងនៃអនុក្រឹត្យបង្កើតគ្រឹះស្ថានសិក្សា ដែលចេញដោយរាជរដ្ឋាភិបាល ឬលិខិតអនុញ្ញាតឱ្យបើកសាលាដែលចេញដោយក្រសួងអប់រំ យុវជន និងកីឡា.................. ០១ច្បាប់
  - ច្បាប់ចម្លងបណ្ណសម្គាល់ខ្លួន ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន......... ០១ច្បាប់
- **សម្រាប់គេហទំព័រប្រភេទ .per.kh**
  - ច្បាប់ចម្លងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែន.................................. ០១ច្បាប់

## ខ. ប្រភេទ និងឈ្មោះគេហទំព័រ

**១**. អ្នកដាក់ពាក្យអាចស្នើសុំមក ន.ទ.ក. ដើម្បីចុះឈ្មោះគេហទំព័រតាមប្រភេទដូចខាងក្រោម៖
- «ឈ្មោះស្នើសុំ».gov.kh សម្រាប់ក្រសួង/ស្ថាប័នរដ្ឋ
- «ឈ្មោះស្នើសុំ».mil.kh សម្រាប់ស្ថាប័នយោធា និងកងកំលាំងប្រដាប់អាវុធ
- «ឈ្មោះស្នើសុំ».com.kh សម្រាប់ក្រុមហ៊ុនឯកជន ឬស្ថាប័នពាណិជ្ជកម្ម
- «ឈ្មោះស្នើសុំ».net.kh សម្រាប់ក្រុមហ៊ុន/ស្ថាប័នផ្តល់សេវាបណ្តាញកុំព្យូទ័រ
- «ឈ្មោះស្នើសុំ».org.kh សម្រាប់អង្គការ និងសមាគមន៍
- «ឈ្មោះស្នើសុំ».edu.kh សម្រាប់គ្រឹះស្ថានសិក្សា សាលាបណ្តុះបណ្តាល និងសកលវិទ្យាល័យ
- «ឈ្មោះស្នើសុំ».per.kh សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ។

**២**. ឈ្មោះគេហទំព័រដែលត្រូវស្នើសុំត្រូវមានចំនួន ០៣ តួអក្សរ/លេខយ៉ាងតិច និង ៦៣ តួអក្សរ/លេខយ៉ាងច្រើន និងត្រូវកំណត់ដូចខាងក្រោម៖
- អាចជាអក្សរឡាតាំងពី «a» ដល់ «z» និងពុំមានភាពខុសគ្នាឡើយសម្រាប់អក្សរតូច និងអក្សរធំ (ឧទាហរណ៍៖ «a» ដល់ «A» សម្គាល់តួអក្សរតែមួយ) ។
- អាចជាលេខ «0, 1, 2, 3, 4, 5, 6, 7, 8» និង/ឬ «9» ។
- សហាសញ្ញា «-» ដែលជាសញ្ញាតែមួយគត់ដែលអនុញ្ញាតឱ្យប្រើប្រាស់នៅក្នុងឈ្មោះស្នើសុំ ប្រសិនបើសញ្ញានេះ មិនត្រូវបានប្រើប្រាស់នៅខាងដើម ឬខាងចុងនៃឈ្មោះ ។
- ករណីស្នើសុំចុះឈ្មោះគេហទំព័រ ដែលមានចំនួន ៣ (បី) តួអក្សរ/លេខ អ្នកស្នើសុំត្រូវភ្ជាប់ជាមួយនូវវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក (Trademark) ឬលិខិតអនុញ្ញាត ឬឯកសារផ្សេងៗសម្គាល់នីតិបុគ្គលដែលមាននាម និងចំនួនតួអក្សរដូចគ្នានឹងឈ្មោះគេហទំព័រដែលបានស្នើសុំ ស្របតាមប្រភេទគេហទំព័រនីមួយៗ ។

- ចំពោះឈ្មោះគេហទំព័រស្នើសុំដោយនីតិបុគ្គលដែលពុំបានចុះបញ្ជីនៅក្រសួងពាក់ព័ន្ធ ឬនីតិបុគ្គលដែលចុះបញ្ជីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ អាចស្នើសុំចុះឈ្មោះគេហទំព័របាន តែត្រូវចុះកិច្ចសន្យាចុះឈ្មោះគេហទំព័រដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី ៦ ។
- ករណីឈ្មោះគេហទំព័រមួយ ត្រូវបានស្នើសុំដោយនីតិបុគ្គលពីរ ឬច្រើន ការអនុញ្ញាតចុះឈ្មោះគេហទំព័រនោះ ត្រូវផ្តល់អាទិភាពជូននីតិបុគ្គលមានវិញ្ញាបនបត្រចុះបញ្ជីម៉ាក ដែលមានឈ្មោះដូចគ្នាទៅនឹងឈ្មោះគេហទំព័រនោះ។

**៣.** ន.ទ.ក. រក្សាសិទ្ធិមិនផ្តល់ការអនុញ្ញាតលើឈ្មោះគេហទំព័រ ដែលប្រើប្រាស់ពាក្យ ឬឃ្លាដូចខាងក្រោម ៖

- «www», «http», «https», «http-www» និងបង្គុំនៃពាក្យទាំងនេះ ។
- មានលក្ខណៈអាសអាភាស រឿងអាស្រូវ មិនសមរម្យ ឬផ្ទុយពីច្បាប់ និងសេចក្តីថ្លៃថ្នូររបស់សង្គមជាតិ ។
- បង្កឱ្យមានការភ័ន្តច្រឡំជាសាធារណៈ ប៉ះពាល់ដល់គោលការណ៍សន្តិសុខ ភាពសុខដុម និងផលប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជា ប្រមាថមើលងាយជំនឿសាសនា និងប៉ះពាល់ជាអវិជ្ជមាននៅក្នុងសង្គម ។

## ឈ. លក្ខខណ្ឌ

អ្នកទទួលលិខិតអនុញ្ញាតត្រូវអនុវត្តដូចតទៅ៖

១. ត្រូវគោរពឱ្យបានត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិដូចមានចែងក្នុងចំណុច (ឃ) និង លិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតដែលនៅជាធរមាន។

២. ត្រូវអនុវត្តស្របតាមលិខិតអនុញ្ញាត និងមិនត្រូវប្រើប្រាស់គេហទំព័រសម្រាប់បង្កផលប៉ះពាល់ដល់សន្តិសុខជាតិដែលត្រូវហាមឃាត់ដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានានៃព្រះរាជាណាចក្រកម្ពុជា។

៣. មិនត្រូវប្រើប្រាស់គេហទំព័រ ដែលមានលក្ខណៈជាល្បែងស៊ីសង (Game) ឬមានមាតិកាអាស-អាភាសនៅលើគេហទំព័ររបស់ខ្លួន ដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសេចក្តីថ្លៃថ្នូររបស់សង្គមជាតិដែលត្រូវហាមឃាត់ដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ។

៤. អ្នកស្នើសុំត្រូវប្រើប្រាស់គំរូទម្រង់ពាក្យសុំដូចខាងក្រោម៖

- <u>ឧបសម្ព័ន្ធទី ២</u> សម្រាប់ការស្នើសុំប្តូរ Name Servers និង IP Addresses ។
- <u>ឧបសម្ព័ន្ធទី ៣</u> សម្រាប់ការស្នើសុំប្តូរព័ត៌មានគេហទំព័រ ។ ព័ត៌មានទំនាក់ទំនងបង់ប្រាក់ថ្មីនឹងត្រូវភ្ជាប់នៅលើវិក្កយបត្រសម្រាប់ឆ្នាំ n ក្នុងករណីអ្នកកាន់កាប់គេហទំព័រស្នើសុំផ្លាស់ប្តូរព័ត៌មានបានមុន ៣០ (សាមសិប) ថ្ងៃមុនដំណាច់ខែធ្នូ នៃឆ្នាំ n-1 ។
- <u>ឧបសម្ព័ន្ធទី ៤</u> សម្រាប់ការស្នើសុំបិទគេហទំព័រ ។ អ្នកកាន់កាប់គេហទំព័រ ត្រូវដាក់ពាក្យស្នើសុំបញ្ឈប់ការប្រើប្រាស់គេហទំព័រមក ន.ទ.ក. ឱ្យបាន ៣០ (សាមសិប) ថ្ងៃ យ៉ាងតិច មុនដំណាច់ខែធ្នូនៃឆ្នាំនីមួយៗ និងភ្ជាប់ជាមួយនូវវិក្កយបត្រនិងបង្កាន់ដៃបង់ប្រាក់ចុងក្រោយ(លើកលែងគេហទំព័រ .gov.kh) ។ ក្នុងករណីអនុវត្តផ្ទុយ អ្នកស្នើសុំត្រូវបង់កម្រៃប្រចាំឆ្នាំនៃឆ្នាំបន្ទាប់ ។
- <u>ឧបសម្ព័ន្ធទី ៥</u> សម្រាប់ការស្នើសុំភ្ជាប់ និងដំណើរការគេហទំព័រឡើងវិញ ។ អ្នកកាន់កាប់គេហទំព័រត្រូវដាក់ពាក្យស្នើសុំភ្ជាប់គេហទំព័រឡើងវិញមក ន.ទ.ក. និងភ្ជាប់ជាមួយនូវវិក្កយបត្រនិងបង្កាន់ដៃបង់ប្រាក់ចុងក្រោយ(លើកលែងគេហទំព័រ .gov.kh) បន្ទាប់ពីទូទាត់បំណុលនិង/ឬប្រាក់ពិន័យទាំងឡាយ ។

៥. ករណីអ្នកកាន់កាប់គេហទំព័របង់ប្រាក់យឺតយ៉ាវលើសពី ៦០ (ហុកសិប) ថ្ងៃ ក្រោយកាលបរិច្ឆេទនៃវិក្កយបត្រ ន.ទ.ក. មានសិទ្ធិលុបឈ្មោះគេហទំព័រនោះ ដោយគ្មានលក្ខខណ្ឌ។
៦. ត្រូវចូលរួមអនុវត្តតាមការណែនាំរបស់មន្ត្រីត្រួតពិនិត្យ នៃ ន.ទ.ក. ។
៧. ក្នុងករណីអនុវត្តផ្ទុយពីសេចក្ដីណែនាំនេះ អ្នកទទួលលិខិតអនុញ្ញាត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ថ្ងៃ អង្គារ ៣កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០១៨

**ប្រធាន**

TELECOMMUNICATION REGULATOR OF CAMBODIA

ស៊ា ណារ៉េត

**ចម្លងជូន៖**

-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
"ដើម្បីជូនជ្រាប"
-ឯកសារ -កាលប្បវត្តិ